ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

---

# ក្រមសីលធម៌

## សម្រាប់

## អ្នកសង្កេតការណ៍បោះឆ្នោតក្នុងដំណើរការបោះឆ្នោត

# មាតិកា


**១- សេចក្តីផ្តើម** ........................................ ១

**២- គោលបំណង** ........................................ ១

**៣- វិសាលភាព** ........................................ ២

**៤- និយមន័យ** ........................................ ២

**៥- សិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវរបស់អ្នកសង្កេតការណ៍បោះឆ្នោត** ........................................ ២

៥.១- សិទ្ធិរបស់អ្នកសង្កេតការណ៍បោះឆ្នោត ........................................ ៣

៥.២- ភារកិច្ចរបស់អ្នកសង្កេតការណ៍បោះឆ្នោត ........................................ ៣

៥.៣- ការទទួលខុសត្រូវរបស់អ្នកសង្កេតការណ៍បោះឆ្នោត ........................................ ៤

**៦- បម្រាមចំពោះអ្នកសង្កេតការណ៍បោះឆ្នោត** ........................................ ៤

**៧- សំណូមពរ និងការអនុវត្ត** ........................................ ៦

៧.១- សំណូមពរ ........................................ ៦

៧.២- ការអនុវត្ត ........................................ ៧

**សម្រង់ទោសប្បញ្ញត្តិ** ........................................ ៨

ក- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ........................................ ៨

ខ- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ........................................ ៩

# អក្សរកាត់

| | | |
|---|---|---|
| ១- | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | គ.ជ.ប |
| ២- | គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | គធ.ខប |
| ៣- | គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត | គឃ.សប |
| ៤- | គណៈកម្មការការិយាល័យបោះឆ្នោត | គ.ក.ប |
| ៥- | គណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត | គ.ក.រ |
| ៦- | លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត | លធ.ខប |
| ៧- | ក្រុមប្រឹក្សាឃុំ សង្កាត់ | កបឃ.សក |
| ៨- | ក្រុមចុះឈ្មោះបោះឆ្នោត | ក.ច.ប |

# ក្រមសីលធម៌

## សម្រាប់

## អ្នកសង្កេតការណ៍បោះឆ្នោតក្នុងដំណើរការបោះឆ្នោត

**១- សេចក្តីផ្តើម**

ប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យ តែងតែប្រាថ្នាចង់ឱ្យរាល់ការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។ ដើម្បីសម្រេចនូវគោលដៅនេះបាន យើងទាំងអស់គ្នាជាប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ក្រសួង ស្ថាប័ន កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ និងភាគីពាក់ព័ន្ធត្រូវរួបរួមគ្នាគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត ព្រមទាំងក្រមសីលធម៌ឱ្យបានខ្ជាប់ខ្ជួន។

ក្រមសីលធម៌នេះ ត្រូវបានរៀបចំតាក់តែងឡើងស្របទៅតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត។

ការប្រតិបត្តិតាមក្រមសីលធម៌ជាផ្នែកមួយដ៏សំខាន់សម្រាប់ធ្វើឱ្យបរិយាកាសនៃដំណើរការបោះឆ្នោត តាំងពីចាប់ផ្តើមរហូតដល់ប្រកាសលទ្ធផលបោះឆ្នោតផ្លូវការប្រព្រឹត្តទៅដោយរលូន និងប្រកបដោយសន្តិសុខ សុវត្ថិភាព។ ការប្រតិបត្តិតាមក្រមសីលធម៌បានល្អជាកត្តាជំរុញលើកទឹកចិត្តដល់ប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ គណបក្សនយោបាយជាគូប្រកួតប្រជែងមានសុទិដ្ឋិនិយមរវាងគ្នានឹងគ្នា សហការគ្នា និងបំពេញការងារតាមភារកិច្ច និងមុខនាទីរៀងៗខ្លួន រួមចំណែកពង្រឹងសាមគ្គីភាព និងកិច្ចសហការជាតិ និងអន្តរជាតិក្នុងការបោះឆ្នោត។ ការគោរពក្រមសីលធម៌បានល្អ នាំឱ្យកាត់បន្ថយបាននូវអំពើហិង្សា ជម្លោះ ការរើសអើង ការបែងចែករវាងអ្នកដែលមាននិន្នាការនយោបាយផ្សេងៗគ្នាក្នុងសង្គម។ ការគោរពក្រមសីលធម៌បានល្អគឺជាការលើកស្ទួយកិត្យានុភាពជាតិលើឆាកអន្តរជាតិ បង្ហាញពីការគោរពច្បាប់ ការឯកភាពជាតិ ការជឿទុកចិត្តគ្នារវាងគណបក្សនយោបាយ ប្រជាពលរដ្ឋ រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធទាំងអស់ក្នុងសង្គម។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) អនុម័តក្រមសីលធម៌នេះ សម្រាប់អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ អនុវត្តក្នុងការសង្កេតមើលដំណើរការបោះឆ្នោតក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារ និងតម្លាភាពនៃការបោះឆ្នោត។

**២- គោលបំណង**

ក្រមសីលធម៌នេះ មានគោលបំណងកំណត់វិធានសំខាន់ៗ សម្រាប់ឱ្យអង្គការមិនមែនរដ្ឋាភិបាល សមាគម និងអ្នកសង្កេតការណ៍បោះឆ្នោត អនុវត្តក្នុងការបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយជំហរអព្យាក្រឹត មិនលម្អៀង ដើម្បីធានាឱ្យ៖

- កិច្ចសង្កេតការណ៍បោះឆ្នោត ត្រូវធ្វើឡើងដោយសុចរិត និងតម្លាភាព
- អ្នកសង្កេតការណ៍បោះឆ្នោតបំពេញការងារដោយពុំមានការជ្រៀតជ្រែក។

## ៣- វិសាលភាព

ក្រមសីលធម៌នេះ មានវិសាលភាពអនុវត្តចំពោះសមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិ អង្គការមិនមែនរដ្ឋាភិបាលបរទេស តំណាងប្រទេសនានា និងអង្គការអន្តរជាតិ និងអ្នកសង្កេតការណ៍ដែលត្រូវបាន គ.ជ.ប អនុញ្ញាតជាផ្លូវការឱ្យសង្កេតការណ៍បោះឆ្នោត។

## ៤- និយមន័យ

វាក្យស័ព្ទសំខាន់ៗនៅក្នុងក្រមសីលធម៌នេះមានន័យដូចតទៅ៖

៤.១- អ្នកសង្កេតការណ៍ជាតិ គឺជាជនជាតិខ្មែរ ឬជនបរទេសដែលជាសមាជិកនៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ឬជនបរទេស ដែលត្រូវបានអញ្ជើញដោយសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលត្រូវបានទទួលស្គាល់ និងអនុញ្ញាតដោយ គ.ជ.ប។

អ្នកសង្កេតការណ៍អន្តរជាតិ គឺជាអ្នកសង្កេតការណ៍នៃអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ អង្គការអន្តរជាតិ និងប្រទេសនានាដែលត្រូវបានអញ្ជើញ និងទទួលស្គាល់ដោយរាជរដ្ឋាភិបាល ហើយនឹងអនុញ្ញាតដោយ គ.ជ.ប។

៤.២- អ្នកសង្កេតការណ៍ជាតិចល័ត សំដៅលើថ្នាក់ដឹកនាំសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលជាតិ ដែលត្រូវបាន គ.ជ.ប សម្រេចទទួលស្គាល់ និងអនុញ្ញាតឱ្យសង្កេតមើលដំណើរការបោះឆ្នោតទូទាំងប្រទេស។

៤.៣- ការបោះឆ្នោត សំដៅដល់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដែលរៀបចំឡើងដោយ គ.ជ.ប។

៤.៤- ដំណើរការបោះឆ្នោត សំដៅលើ៖

- ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត
- ការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត
- ការឃោសនាបោះឆ្នោត
- ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផលនៃការបោះឆ្នោត
- ការដាក់ ការទទួល និងការដោះស្រាយបណ្ដឹង
- ការប្រកាសលទ្ធផលនៃការបោះឆ្នោត។

## ៥- សិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវរបស់អ្នកសង្កេតការណ៍បោះឆ្នោត

បន្ទាប់ពី គ.ជ.ប បានទទួលស្គាល់ជាផ្លូវការហើយ អ្នកសង្កេតការណ៍ទាំងឡាយមានសិទ្ធិធ្វើសកម្មភាពសង្កេតការណ៍បោះឆ្នោត ដោយឯករាជ្យពីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង គ.ជ.ប ព្រមទាំងទទួលនូវកិច្ចសហប្រតិបត្តិការយ៉ាងពេញទំហឹងពីអាជ្ញាធរដែនដី គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់។

សិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវរបស់អ្នកសង្កេតការណ៍ មានដូចខាងក្រោម។

### ៥.១- សិទ្ធិរបស់អ្នកសង្កេតការណ៍បោះឆ្នោត

នៅពេលត្រូវបានទទួលស្គាល់ជាផ្លូវការ និងទទួលបានបណ្ណសម្គាល់អ្នកសង្កេតការណ៍រួចហើយ អ្នកសង្កេតការណ៍ទាំងឡាយមានសិទ្ធិដូចខាងក្រោម៖

៥.១.១ អ្នកសង្កេតការណ៍ជាតិអាចធ្វើដំណើរសង្កេតការណ៍ក្នុងរាជធានី ខេត្ត ដែលអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមរបស់ខ្លួនបានស្នើសុំប៉ុណ្ណោះ លើកលែងតែអ្នកសង្កេតការណ៍ជាតិចល័តទូទាំងប្រទេសដែលត្រូវបានអនុញ្ញាត និងផ្តល់បណ្ណសម្គាល់ខ្លួនដោយ គ.ជ.ប។

៥.១.២ អ្នកសង្កេតការណ៍អន្តរជាតិអាចធ្វើដំណើរទៅគ្រប់ទីកន្លែងក្នុងដែនដី នៃព្រះរាជាណាចក្រកម្ពុជាដោយពុំចាំបាច់មានការអនុញ្ញាត ឬជូនដំណឹងជាមុនឡើយ លើកលែងតែដោយសារមូលហេតុច្បាស់លាស់ទាក់ទងនឹងសន្តិសុខផ្ទាល់ខ្លួនប៉ុណ្ណោះ។

៥.១.៣ ក្នុងករណីជួបគ្រោះអាសន្ន ឬអសន្តិសុខអ្វីមួយ អ្នកសង្កេតការណ៍ត្រូវជូនដំណឹងទៅមន្ត្រីបោះឆ្នោត និងអាជ្ញាធរដែនដីពាក់ព័ន្ធ ដើម្បីជួយដោះស្រាយទាន់ពេលវេលា។

៥.១.៤ អមដំណើរជាមួយក្រុមចុះឈ្មោះបោះឆ្នោត (ក.ច.ប) គណៈកម្មការការិយាល័យបោះឆ្នោត (គ.ក.ប) លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) និង គ.ជ.ប នៅរាល់ពេលដឹកជញ្ជូនសម្ភារ បរិក្ខារចុះឈ្មោះបោះឆ្នោត ហិបឆ្នោត និងសម្ភារបោះឆ្នោត។

៥.១.៥ សង្កេតការណ៍នូវរាល់សកម្មភាពរបស់ លធ.ខប ក.ច.ប ក្រុមប្រឹក្សាឃុំ សង្កាត់ (កឃ.ស) ឬ គ.ក.ប ឬ គឃ.សប ឬ គធ.ខប និង គ.ជ.ប នៅមុនពេល ក្នុងពេល និងក្រោយពេលចុះឈ្មោះបោះឆ្នោត ឬបោះឆ្នោត តាមប្រតិទិនកំណត់ដោយ គ.ជ.ប។

៥.១.៦ ចេញ ចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដោយមិនត្រូវបង្កការរំខាន។

៥.១.៧ ជួប ឬនិយាយ ឬលើកសំណួរជាមួយបេក្ខជន ឬគណបក្សនយោបាយ និងមន្ត្រីបោះឆ្នោត នៅក្រៅការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ហើយកម្មវត្ថុនៃការជជែកនោះ មិនទាក់ទងនឹងការគាំទ្រ ឬប្រឆាំងនឹងបេក្ខជន ឬគណបក្សនយោបាយណាមួយ។

### ៥.២- ភារកិច្ចរបស់អ្នកសង្កេតការណ៍បោះឆ្នោត

អ្នកសង្កេតការណ៍ទាំងឡាយមានភារកិច្ចដូចខាងក្រោម៖

៥.២.១ ត្រូវគោរពច្បាប់ដែលមានជាធរមាននៅព្រះរាជាណាចក្រកម្ពុជា និងត្រូវទទួលស្គាល់ និងគោរពអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជា។

៥.២.២ ត្រូវយល់ដឹងពីច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត។ ក្នុងករណីមានការរំលោភច្បាប់បោះឆ្នោត និងបទបញ្ជា និងនីតិវិធី ត្រូវធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួនដោយផ្អែកលើមូលដ្ឋានឯកសារត្រឹមត្រូវ ព្រមទាំងភស្តុតាងច្បាស់លាស់ និងអាចពន្យល់បញ្ជាក់បាន។

៥.២.៣ ត្រូវមានឥរិយាបថអព្យាក្រឹត និងមិនត្រូវប្រកាន់បក្សពួក ហើយត្រូវជៀសវាងក្នុងការបង្ហាញឱ្យគេឃើញតាមរយៈឯកសណ្ឋានពណ៌ ឬវត្ថុដទៃទៀត ដែលជានិមិត្តរូបនៃការគាំទ្រ ឬការប្រឆាំងនឹងបេក្ខជន ឬគណបក្សនយោបាយណាមួយ។

៥.២.៤ រក្សាការសម្ងាត់នៃការបោះឆ្នោត។

៥.២.៥ ត្រូវបង្ហាញភស្តុតាងបញ្ជាក់អំពីអត្តសញ្ញាណរបស់ខ្លួនភ្លាមដល់អាជ្ញាធរមានសមត្ថកិច្ចដែលបានសាកសួរខ្លួន ហើយត្រូវពាក់បណ្ណសម្គាល់ខ្លួន ដែលត្រូវបានសម្រេចទទួលស្គាល់ និងចេញឱ្យដោយ លធ.ឃប ឬ គធ.ឃប ឬ គ.ជ.ប។

៥.២.៦ ត្រូវប្រតិបត្តិតាមគោលការណ៍ណែនាំ និងនីតិវិធី ដែលបានកំណត់ដោយ គ.ជ.ប និងការណែនាំរបស់មន្ត្រីបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតនៅថ្នាក់ក្រោម ហើយមិនត្រូវធ្វើឱ្យរាំងស្ទះដល់ដំណើរនៃការបោះឆ្នោត ក្នុងអំឡុងពេលចុះសង្កេតការណ៍នៅការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតណាមួយ។

៥.២.៧ ធ្វើរបាយការណ៍ស្តីពីការរកឃើញ ការកត់សម្គាល់ និងសេចក្តីសន្និដ្ឋានរបស់ខ្លួនឆ្លងតាមរយៈថ្នាក់ដឹកនាំរបស់ខ្លួន ដោយផ្អែកតាមការណែនាំជាកំណត់របស់ថ្នាក់ដឹកនាំ ឬអង្គការរបស់ខ្លួន។

៥.២.៨ ធ្វើរបាយការណ៍អំពីការរំលោភច្បាប់ ឬបទបញ្ជា និងនីតិវិធី ដែលត្រូវបានចោទប្រកាន់ និងអំពីភាពមិនប្រក្រតីនានាជូនថ្នាក់ដឹកនាំផ្ទាល់របស់ខ្លួន និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធ និងអាចធ្វើរបាយការណ៍អំពីបញ្ហាធ្ងន់ធ្ងរនានាជាបន្ទាន់ ជូនគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធ និងត្រូវផ្ញើរបាយការណ៍នេះ ១ (មួយ) ច្បាប់ ទៅ គ.ជ.ប ផង។

៥.២.៩ ត្រូវគោរពតាមការកំណត់របស់ប្រធាន ក.ច.ប ឬ គ.ក.ប/គ.ក.រ ដែលតម្រូវឱ្យផ្លាស់ប្តូរគ្នាចូលសង្កេតការណ៍ម្តង ៤ (បួន) នាក់ ក្នុងករណីមានអ្នកសង្កេតការណ៍ច្រើនលើសពី ៤ (បួន) នាក់ សម្រាប់ការិយាល័យមួយ។

## ៥.៣- ការទទួលខុសត្រូវរបស់អ្នកសង្កេតការណ៍បោះឆ្នោត

អង្គការមិនមែនរដ្ឋាភិបាល ឬសមាគម ឬ/និងអ្នកសង្កេតការណ៍ត្រូវទទួលខុសត្រូវលើសកម្មភាពរបស់ខ្លួនទៅតាមច្បាប់ជាធរមាន។

អង្គការមិនមែនរដ្ឋាភិបាល ឬសមាគម ឬ/និងអ្នកសង្កេតការណ៍ត្រូវទទួលបន្ទុកចំណាយរបស់ខ្លួននៅក្នុងអំឡុងពេលនៃបេសកកម្មសង្កេតការណ៍របស់ខ្លួន។

## ៦- ហាមឃាត់ចំពោះអ្នកសង្កេតការណ៍បោះឆ្នោត

ក្នុងការសង្កេតមើលការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ការឃោសនាបោះឆ្នោត និងរាល់សកម្មភាពនានានៅការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត នៅមុនពេល ក្នុងពេល និងក្រោយពេលនៃការបោះឆ្នោតអ្នកសង្កេតការណ៍មិនត្រូវ៖

៦.១ ជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃព្រះរាជាណាចក្រកម្ពុជា។

៦.២ ជជែកពិភាក្សាទាក់ទងនឹងបញ្ហាគាំទ្រ ឬប្រឆាំងគណបក្សនយោបាយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោតណាមួយ ជាមួយនឹងអ្នកចុះឈ្មោះបោះឆ្នោត ឬអ្នកបោះឆ្នោត។

៦.៣ យកតាមខ្លួននូវគ្រឿងអាវុធ ជាតិផ្ទុះ ឬវត្ថុដែលអាចបង្កឱ្យមានគ្រោះថ្នាក់ក្នុងអំឡុងពេលបំពេញភារកិច្ចសង្កេតការណ៍របស់ខ្លួន។

៦.៤ បញ្ចុះបញ្ចូល ឬប្រមូលផ្តុំប្រជាពលរដ្ឋឱ្យចូលរួមឃោសនា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៥ ចូលរួមក្នុងក្បួនដង្ហែ ឬការប្រជុំរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៦ ចូលរួមផ្សព្វផ្សាយគោលនយោបាយ ឬសម្ភារឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៧ ចូលជាសមាជិកគណៈកម្មការឃោសនាបោះឆ្នោតនៃគណបក្សនយោបាយណាមួយ។

៦.៨ ស្វែងមតិក្នុងគោលបំណងបម្រើឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៩ សរសេរជាលាយលក្ខណ៍អក្សរ ឬផ្តល់បទសម្ភាសន៍ដល់ប្រព័ន្ធផ្សព្វផ្សាយ ក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១០ និយាយដោយផ្ទាល់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរ ក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១១ និយាយដោយផ្ទាល់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរ ក្នុងន័យប្រមាថមាក់ងាយគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១២ ដាក់តាំង ឬបិទផ្សាយរូបភាព ឬឯកសារផ្សេងៗ ភ្ជាប់នឹងយានយន្តរបស់អង្គការខ្លួន ឬនៅក្នុងបរិវេណនៃទីកន្លែងធ្វើការរបស់ខ្លួន ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១៣ ផ្តល់យានយន្តគ្រប់ប្រភេទ ដើម្បីជាមធ្យោបាយសម្រាប់ការឃោសនារបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១៤ ផ្តល់ថវិកា សម្ភារ និងបរិក្ខារប្រើប្រាស់ផ្សេងៗជូនប្រជាពលរដ្ឋ សម្រាប់ចូលរួមក្នុងសកម្មភាពឃោសនា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១៥ ផ្តល់ថវិកា សម្ភារ និងបរិក្ខារសម្រាប់ដង្ហែក្បួនឃោសនា ការជួបជុំជាសាធារណៈ ការសម្តែងសិល្បៈ និងការបោះពុម្ពសម្ភារឃោសនា ទោះដោយផ្ទាល់ក្តី ឬប្រយោលក្តី ដើម្បីគាំទ្រគណបក្សនយោបាយបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១៦ រំខាន ឬជ្រៀតជ្រែកក្នុងកិច្ចការផ្សេងៗរបស់គណៈកម្មការរៀបចំការបោះឆ្នោតនៅថ្នាក់ណាមួយ នៅពេលដំណើរការនៃការចុះឈ្មោះបោះឆ្នោត ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតកំពុងប្រព្រឹត្តទៅ។

៦.១៧ ប៉ះពាល់ឯកសារ ឬសម្ភារ បរិក្ខារបោះឆ្នោត ក្នុងនោះរួមទាំងសន្លឹកឆ្នោតផង។

៦.១៨ ប្រើប្រាស់ម៉ាស៊ីនថតរូប ថតវីដេអូ ថតសំឡេង ឬទូរសព្ទថតរូប ឬឧបករណ៍ថតរូបផ្សេងៗ នៅក្នុងការិយាល័យបោះឆ្នោត។

៦.១៩ នៅក្បែរបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត។

៦.២០ ផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត និងមន្ត្រីរាប់សន្លឹកឆ្នោត និងបង្អាក់ដំណើរការបោះឆ្នោត។

៦.២១ រំលោភទៅលើបទប្បញ្ញត្តិទាំងឡាយនៃច្បាប់បោះឆ្នោត ឬបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត។

៦.២២ ចូលរួមជជែកវែកញែក ក្នុងដំណើរការដោះស្រាយបណ្តឹងណាមួយក្នុងអំឡុងពេលបោះឆ្នោត ប៉ុន្តែអាចសង្កេតការណ៍លើការដោះស្រាយបណ្តឹងនេះបាន។

៦.៤២ ការជក់បារី និងការបង្ការភ្លើង អគ្គិភ័យ

អ្នកសង្កេតការណ៍បោះឆ្នោត ត្រូវជៀសវាង៖

- ការជក់បារីនៅក្នុងទីស្តីការ គ.ជ.ប ទីស្នាក់ការ លធ.ឧប ទីស្នាក់ការគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត
- ការគូសឈើគូស កេះដែកកេះ ឬឧបករណ៍ដែលអាចធ្វើឱ្យឆេះណាមួយនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដោយគ្មានការចាំបាច់តម្រូវឱ្យធ្វើ។

៦.៤៣ ល្បែង

អ្នកសង្កេតការណ៍បោះឆ្នោត មិនត្រូវលេងល្បែងស៊ីសង ឬល្បែងកំសាន្តនៅក្នុងទីស្តីការ គ.ជ.ប ទីស្នាក់ការ លធ.ឧប ទីស្នាក់ការគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

## ៧- សំណូមពរ និងការអនុវត្ត

អង្គការមិនមែនរដ្ឋាភិបាល សមាគម និងអ្នកសង្កេតការណ៍ត្រូវយកចិត្តទុកដាក់អនុវត្តដូចខាងក្រោម។

### ៧.១- សំណូមពរ

បន្ទាប់ពីដំណើរការបោះឆ្នោតបានចប់សព្វគ្រប់ហើយ សាមីអង្គការសង្កេតការណ៍ទាំងឡាយត្រូវផ្តល់របាយការណ៍ជាលាយលក្ខណ៍អក្សរស្តីពីការសង្កេតឃើញ និងសេចក្តីសន្និដ្ឋានរបស់ខ្លួន នៅក្នុងដំណើរការបោះឆ្នោត ផ្ញើជូន គ.ជ.ប។ គ.ជ.ប មានសិទ្ធិផ្តល់យោបល់លើរបាយការណ៍នេះ។ អង្គការសង្កេតការណ៍បោះឆ្នោតអាចធ្វើការកែតម្រូវ ឬមិនកែតម្រូវតាមយោបល់របស់ គ.ជ.ប។ ក្នុងករណីមិនធ្វើការកែតម្រូវតាមយោបល់របស់ គ.ជ.ប ត្រូវភ្ជាប់យោបល់នេះ នៅក្នុងផ្នែកចុងក្រោយនៃរបាយការណ៍របស់ខ្លួនដែលត្រូវផ្សព្វផ្សាយ។

**៧.២- ការអនុវត្ត**

ក្រមសីលធម៌នេះ មានប្រសិទ្ធភាពអនុវត្តចាប់តាំងពីថ្ងៃចុះហត្ថលេខាដោយប្រធាន គ.ជ.ប និងត្រូវអនុវត្តគ្រប់សម័យកាលនៃការបោះឆ្នោត ដែលរៀបចំឡើងដោយ គ.ជ.ប។

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

ស៊ិក ប៊ុនហុក

# សម្រង់ទោសប្បញ្ញត្តិ

## ក- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

**មាត្រា១៤២ .-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណា ដែលតាមគ្រប់មធ្យោបាយទុច្ចរិតៈ

- រារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។
- បង្កការអុកឡុក ឬរារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោត។
- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។
- រារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។
- រារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោត តាមការកំណត់។
- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។
- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។
- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។
- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។
- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬលុបបេក្ខភាពរបស់សាមីខ្លួន ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

**មាត្រា១៤៨ .-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមអន្តរជាតិដែលបំពេញការងារ

ក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាដែលបានធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោល បំពានលើបញ្ញត្តិនៃមាត្រា ៨៤ នៃច្បាប់នេះ។

ការទទួលខុសត្រូវខាងលើ មិនលើកលែងការទទួលខុសត្រូវរបស់រូបវន្តបុគ្គលចំពោះអំពើដដែលខាងលើ ឬបទល្មើសផ្សេងទៀតដែលបានបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌនោះឡើយ។

**មាត្រា១៥៨ .-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀលទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនបរទេសដែលមានវត្តមាននៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលក្នុងចេតនាឃោសនាបោះឆ្នោត ដើម្បីគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

ជនប្រព្រឹត្តអំពើខាងលើ អាចត្រូវបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា តាមបែបបទដូចបានចែងក្នុងច្បាប់ស្តីពីអន្តោប្រវេសន៍។

**មាត្រា១៥៩ .-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ដែលប្រព្រឹត្តអំពើបំពានមាត្រា ១៣៧ នៃច្បាប់នេះ។

ការទទួលខុសត្រូវខាងលើ មិនលើកលែងការទទួលខុសត្រូវរបស់រូបវន្តបុគ្គល ចំពោះអំពើដដែលខាងលើ ឬបទល្មើសផ្សេងទៀតដែលបានបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌនោះឡើយ។

**មាត្រា១៦០ .-**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ចំពោះភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ដែលផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត ឬមន្ត្រីរាប់សន្លឹកឆ្នោត។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**ខ- សម្រាប់មាត្រាអំពីទោសបញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់**

**មាត្រា១៧១ .-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយទុច្ចរិតៈ

- រារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬរាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។

- បង្កការរុករាន ឬរារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោត។
- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។
- រារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។
- រារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោត តាមការកំណត់។
- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។
- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។
- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។
- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។
- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬលុបបេក្ខភាពរបស់សាមីខ្លួន ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

**មាត្រា១៧៩ .-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមអន្តរជាតិដែលបំពេញការងារក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលបំពានលើបញ្ញត្តិនៃមាត្រា ៧៤ នៃច្បាប់នេះ។

ការទទួលខុសត្រូវខាងលើ មិនលើកលែងការទទួលខុសត្រូវរបស់រូបវន្តបុគ្គលចំពោះអំពើដដែលខាងលើ ឬបទល្មើសផ្សេងទៀតដែលបានបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌនោះឡើយ។

**មាត្រា១៨០ .-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀលទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនបរទេសដែលមានវត្តមាននៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលក្នុងចេតនាឃោសនាបោះឆ្នោត ដើម្បីគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

ជនប្រព្រឹត្តអំពើខាងលើ អាចត្រូវបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជាតាមបែបបទដូចបានចែងក្នុងច្បាប់ស្តីពីអន្តោប្រវេសន៍។

**មាត្រា១៨៧ .—**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ដែលប្រព្រឹត្តអំពើបំពានមាត្រា ១៥៩ នៃច្បាប់នេះ។

ការទទួលខុសត្រូវខាងលើ មិនលើកលែងការទទួលខុសត្រូវរបស់រូបវន្តបុគ្គលចំពោះអំពើដដែលខាងលើ ឬបទល្មើសផ្សេងទៀតដែលបានបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌនោះឡើយ។

**មាត្រា១៨៨ .—**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ឬប្រធានគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត ចំពោះភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ដែលផ្ដល់ការណែនាំ ឬស្ដីបន្ទោសដល់មន្ត្រីបោះឆ្នោត ឬមន្ត្រីរាប់សន្លឹកឆ្នោត។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។